


# ការទទួលបានសញ្ញាប័ត្រ ៖ ល័ក្ខខ័ណ្ឌតម្រូវឲ្យមានសម្រាប់ការបញ្ចប់ការសិក្សារបស់រដ្ឋ

ល័ក្ខខ័ណ្ឌតម្រូវឲ្យមានសម្រាប់ការបញ្ចប់ការសិក្សារបស់រដ្ឋរបស់យើង គឺរៀបចំឡើងដើម្បីធានាឲ្យសិស្សគ្រប់រូបមានជំនាញ មូលដ្ឋានរឹងមាំក្នុងមុខវិជ្ជាអាន សរសេរ គណិតសាស្ត្រនិងវិទ្យាសាស្ត្រ មិនចំពោះថា មុខវិជ្ជាដែលពួកគេជ្រើសរើសយក បន្ទាប់ពីពេលចប់មធ្យមសិក្សាទុតិយភូមិ ទេ ។ យើងលើកទឹកចិត្តឲ្យគ្រួសារនិងសិស្ស ឲ្យជួបជាមួយ អ្នកឲ្យឱវាទផ្នែកអប់រំសិក្សានៅតាមសាលារៀន របស់ពួកគេទទួលបានការសិក្សាអប់រំស្របតាមល័ក្ខខ័ណ្ឌតម្រូវសការបញ្ចប់ការសិក្សា។

យើងសូមលើកទឹកចិត្តឲ្យគ្រួសារ និងសិស្ស ទៅជួបអ្នកផ្តល់ឱវាទផ្នែកសិក្សាអប់រំនៅតាមសាលារៀនរបស់ពួកគេ ឲ្យបានជាប់ជាប្រក្រតី ដើម្បីធានាថា ពួកគេទទួលបានការ សិក្សាអប់រំស្រប ទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ការបញ្ចប់ការសិក្សា។ ដើម្បីឲ្យមានលក្ខណសម្បត្តិបញ្ចប់ការសិក្សានៅក្នុងរដ្ឋវ៉ាស៊ីនតោនទទៅបាន, សិស្សមធ្យមសិក្សាទុតិយ ភូមិគ្រប់រូបត្រូវតែ ៖ ប្រឡងជាប់វិញ្ញាសាជាក់លាក់របស់រដ្ឋ; ទទួលបានគ្រប់ក្រេឌិដតម្រូវទាំងអស់របស់រដ្ឋ និងបណ្ឌលសិក្សាធិការ; ព្រមទាំងបំពេញចប់ផែនការមធ្យមសិក្សាទុតិយភូមិឡើងទៅ ល័ក្ខខ័ណ្ឌតម្រូវសម្រាប់ការវាស់ស្ទង់មានដូចតទៅ ៖

- **សម្រាប់ឆ្នាំសិក្សា 2012 ៖** សិស្សគ្រប់រូបត្រូវតែប្រឡងជាប់តេស្ត**អាន**និង**សរសេរ**រដ្ឋរបស់ មុខវិជ្ជាតាមជំរើសផ្សេងទៀតដែលអនុម័តទទួលស្គាល់ដោយរដ្ឋឬការវាស់ស្ទង់វិញ្ញាសាចំណេះដឹងសំរាប់សិស្ស នៅក្នុងកម្មវិធីអប់រំពិសេស ។ សិស្សគ្រប់រូបអាចជួបតាមល័ក្ខខ័ណ្ឌតម្រូវផ្នែក**គណិតសាស្ត្រ**របស់រដ្ឋ ដោយការប្រឡងជាប់តេស្តគណិតសាស្ត្រនៅ មធ្យមសិក្សាទុតិយភូមិ**ឬ**តាមរយៈការរៀនយក មុខវិជ្ជាគណិតសាស្ត្រឲ្យបានពីរក្រេឌិតបន្ទាប់ពីថ្នាក់ទី 10 ។
- **ឆ្នាំសិក្សា 2013 និង 2014 ៖** សិស្សគ្រប់រូបនឹងត្រូវបានតម្រូវឲ្យប្រឡងជាប់វិញ្ញាសារបស់រដ្ឋក្នុងមុខវិជ្ជា **អាន**និង**សរសេរ** ហើយនិងវិញ្ញាសាប្រឡងថ្នាក់បញ្ចប់ មុខវិជ្ជា**គណិតសាស្ត្រ**មួយថ្នាក់ វិញ្ញាសាតាមជំរើសផ្សេងទៀតដែល អនុម័តទទួលស្គាល់ដោយរដ្ឋ ឬការវាស់ស្ទង់វិញ្ញាសា ចំណេះដឹងសំរាប់សិស្សនៅក្នុងកម្មវិធីអប់រំពិសេស។
- **ឆ្នាំសិក្សា 2015 និងតទៅ៖** សិស្សគ្រប់រូប ត្រូវតែប្រឡងជាប់តេស្តរដ្ឋក្នុងមុខវិជ្ជា**អាន** និង**សរសេរ** ហើយនិងវិញ្ញាសាប្រឡងបញ្ចប់មុខវិជ្ជា **ពិជគណិតថ្នាក់ទី 1 រេខាគណិត** និង **ជីវវិទ្យា** វិញ្ញាសាតាមជំរើសផ្សេងទៀតដែលអនុម័តទទួលស្គាល់ដោយរដ្ឋ ឬការវាស់ស្ទង់វិញ្ញាសាចំណេះដឹងសំរាប់ សិស្សនៅក្នុងកម្មវិធីអប់រំពិសេស ។

សំរាប់ព័ត៌មានពិស្តារបន្ថែម សូមមើលតារាងនៅខាងក្រោម និយាយជាមួយអ្នកផ្តល់ឱវាទផ្នែកអប់រំរបស់ អ្នកឬមើលវ៉ិបសាយ ៖ www.k12.wa.us/GraduationRequirements.

**កំណត់សំគាល់ ៖** ឆ្នាំបញ្ចប់ការសិក្សាត្រូវបានកំណត់នៅពេលសិស្សឈានចូលដល់ថ្នាក់ទីប្រាំបួន

| សម្រាប់ឆ្នាំសិក្សា 2012 | ឆ្នាំសិក្សា 2013 និង 2014 | ឆ្នាំសិក្សា 2015 ឡើងទៅ |
|---|---|---|
| **មុខវិជ្ជាអាន និងសរសេរ**<br>**ប្រឡងជាប់**វិញ្ញាសា HS WASL/HSPE ឬវិញ្ញាសាវាស់ស្ទង់ចំណេះដឹង សម្រាប់សិស្សក្នុងកម្មវិធីអប់រំពិសេស ក្នុងមុខវិជ្ជាអាន និងសរសេរ។<br>—ឬ—<br>**ប្រឡងជាប់**វិញ្ញាសាតាមជំរើសផ្សេងទៀតដែលអនុម័តទទួលស្គាល់ដោយរដ្ឋ។ * | **មុខវិជ្ជាអាន និងសរសេរ**<br>**ប្រឡងជាប់**វិញ្ញាសា HSPE ឬវិញ្ញាសាវាស់ស្ទង់ចំណេះដឹងសម្រាប់ សិស្សក្នុងកម្មវិធីអប់រំពិសេស ក្នុងមុខវិជ្ជាអាន និងសរសេរ។<br>—ឬ—<br>**ប្រឡងជាប់**វិញ្ញាសាតាមជំរើសផ្សេងទៀតដែលអនុម័តទទួលស្គាល់ ដោយរដ្ឋ។ * | **មុខវិជ្ជាអាន និងសរសេរ**<br>**ប្រឡងជាប់**វិញ្ញាសា HSPE ឬវិញ្ញាសាវាស់ស្ទង់ចំណេះដឹងសម្រាប់ សិស្សក្នុងកម្មវិធីអប់រំពិសេស ក្នុងមុខវិជ្ជាអាន និងសរសេរ។<br>—ឬ—<br>**ប្រឡងជាប់**វិញ្ញាសាតាមជំរើសផ្សេងទៀតដែលអនុម័តទទួលស្គាល់ ដោយរដ្ឋ។ * |
| **មុខវិជ្ជាគណិតសាស្ត្រ**<br>**ប្រឡងជាប់**វិញ្ញាសា WASL/HSPE នៃមធ្យមសិក្សាទុតិយភូមិ វិញ្ញាសាប្រឡងបញ្ចប់មុខវិជ្ជាមួយថ្នាក់ ឬការវាស់ស្ទង់វិញ្ញាសារចំណេះដឹងសំរាប់សិស្ស នៅក្នុងកម្មវិធីអប់រំពិសេស ។<br>—ឬ—<br>**ប្រឡងជាប់**វិញ្ញាសាតាមជំរើសផ្សេងទៀតដែលអនុម័តទទួលស្គាល់ដោយរដ្ឋ។ *<br>—ឬ—<br>**រៀនយក**មុខវិជ្ជាណិតសាស្ត្រឲ្យបានពីរក្រេឌិដ (ឬមុខវិជ្ជាផ្នែកវិជ្ជាជីវៈ និង បច្ចេកវិទ្យាដែលប្រហាក់ប្រហែលគ្នា) បន្ទាប់ពីថ្នាក់ទី 10 ។ * | **មុខវិជ្ជាគណិតសាស្ត្រ**<br>**ប្រឡងជាប់**វិញ្ញាសាប្រឡងបញ្ចប់មុខវិជ្ជាគណិតសាស្ត្រ មួយថ្នាក់ ០ពិជគណិតថ្នាក់ទី 1 ឬ រេខាគណិត០ ឬការវាស់ស្ទង់វិញ្ញាសាចំណេះដឹងសំរាប់សិស្ស នៅក្នុងកម្មវិធីអប់រំពិសេស។<br>—ឬ—<br>**ប្រឡងជាប់**វិញ្ញាសាតាមជំរើសផ្សេងទៀតដែលអនុម័តទទួលស្គាល់ ដោយរដ្ឋ។ * | **មុខវិជ្ជាគណិតសាស្ត្រ**<br>**ប្រឡងជាប់**វិញ្ញាសាប្រឡងបញ្ចប់មុខវិជ្ជា ឬវិញ្ញាសាវាស់ស្ទង់ចំណេះដឹង សម្រាប់សិស្សក្នុងកម្មវិធីអប់រំពិសេស ក្នុងមុខវិជ្ជាគណិតសាស្ត្រ។<br>—ឬ—<br>**ប្រឡងជាប់**វិញ្ញាសាតាមជំរើសផ្សេងទៀតដែលអនុម័តទទួលស្គាល់ ដោយរដ្ឋ។ * |
| | **មុខវិជ្ជាវិទ្យាសាស្ត្រ**<br>អស់មានការតំរូវសំរាប់សិស្សគ្រប់រូបនៅក្នុងការប្រឡងជាប់វិញ្ញាបនប័ត្រទាំងពីរនេះដូចដែលបានអនុម័តហត្ថលេខានៅក្នុងច្បាប់ចុះ ថ្ងៃទី 7 ខែមិថុនា ឆ្នាំ 2011០។ | **មុខវិជ្ជាវិទ្យាសាស្ត្រ**<br>**ប្រឡងជាប់**វិញ្ញាសាប្រឡងបញ្ចប់មុខវិជ្ជាជីវសាស្ត្រ ឬការវាស់ស្ទង់វិញ្ញាសាចំណេះដឹងសំរាប់សិស្សនៅក្នុងកម្មវិធីអប់រំពិសេស។ —ឬ—<br>**ប្រឡងជាប់**វិញ្ញាសាតាមជំរើសផ្សេងទៀតដែលអនុម័តទទួលស្គាល់ ដោយរដ្ឋ។ * |
| **លក្ខខណ្ឌតម្រូវផ្សេងៗទៀត**<br>**បំពេញតាម**លក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សាផ្សេងៗទៀតរបស់រដ្ឋ និង មណ្ឌលសិក្សាធិការ ៖ លក្ខខណ្ឌតម្រូវនៃគម្រោង Culminating Project, ផែនការ High School and Beyond Plan, និងក្រេឌិដ ទៅតាមការតម្រូវ នៃមណ្ឌលសិក្សាធិការនីមួយៗ។ | **លក្ខខណ្ឌតម្រូវផ្សេងៗទៀត**<br>**បំពេញតាម**លក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សាផ្សេងៗទៀតរបស់រដ្ឋ និង មណ្ឌលសិក្សាធិការ ៖ លក្ខខណ្ឌតម្រូវនៃគម្រោង Culminating Project, ផែនការ High School and Beyond Plan, និងក្រេឌិដ ទៅតាមការតម្រូវនៃមណ្ឌលសិក្សាធិការនីមួយៗ។ | **លក្ខខណ្ឌតម្រូវផ្សេងៗទៀត**<br>**បំពេញតាម**លក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សាផ្សេងៗទៀតរបស់រដ្ឋ និង មណ្ឌលសិក្សាធិការ ៖លក្ខខណ្ឌតម្រូវនៃគម្រោង Culminating Project, ផែនការ High School and Beyond Plan, និងក្រេឌិដ ទៅតាមការតម្រូវ នៃមណ្ឌលសិក្សាធិការនីមួយៗ។ |

* សិស្សគ្រប់រូបត្រូវតែប្រឡងថ្នាក់វិញ្ញាសារមធ្យមសិក្សាទុតិយភូមិនីមួយៗ យ៉ាងហោចណាស់មួយវិញ្ញាសារ នៅមុនពេលការប្រើវិញ្ញាសាតាមជំរើសផ្សេងទៀតដែល អនុម័តទទួលស្គាល់ដោយរដ្ឋ។ បទបញ្ញត្តិផ្សេងៗគ្នា គឺអនុវត្តសំរាប់ការប្រមូលផ្តុំភស្តុតាង ។

**ធ្វើបច្ចុប្បភាពក្នុងខែ កក្កដា ឆ្នាំ 2011**

# លក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សា និងតេស្តរបស់រដ្ឋវ៉ាស៊ីនតោន

## ការប្រឡងវិញ្ញាសាថ្នាក់មធ្យមសិក្សាទុតិយភូមិរបស់រដ្ឋ

- ក្នុងរដូវស្លឹកឈើលាស់ឆ្នាំ 2011, មុខវិញ្ញាសា បញ្ចប់ការប្រឡងពីរមុខក្នុងមុខវិជ្ជា ពិជគណិតថ្នាក់ទី 1 (algebra 1) និងរេខាគណិត (geometry) ដែលបានជំនួសដោយវិញ្ញាសាគណិតសាស្ត្រ HSPE ។
- ក្នុងពេលចាប់ផ្តើមរដូវស្លឹកឈើលាស់ឆ្នាំ 2012, មុខវិញ្ញាសារបញ្ចប់ការប្រឡងក្នុងមុខវិជ្ជា ជីវសាស្ត្រ (biology) នឹងត្រូវបានជំនួសដោយ វិញ្ញាសាវិទ្យាសាស្ត្រ HSPE ។
- សិស្សមានឱកាសទទួលបានមូលនិធិឧបត្ថម្ភដោយ រដ្ឋចំនួនប្រាំ នៅក្នុងអំឡុងកំពុងសិក្សាក្នុងមធ្យម សិក្សាទុតិយភូមិ ដើម្បីប្រឡងវិញ្ញាសារនៅក្នុងមុខ វិជ្ជានិមួយៗ ។
- សិស្សប្រឡងជាប់វិញ្ញាសា ដោយទទួលបានពិន្ទុកម្រិត Level 3 ឬ 4 ។
- និតិវិធីឧទ្ធរណ៍ពិន្ទុ ៖ ឪពុកម្តាយ/អ្នកអាណាព្យាបាល បន្ទាប់ពីបានពិនិត្យមើលលទ្ធផលតេស្តមធ្យមសិក្សាទុតិយភូមិរបស់សិស្សពួកគេរួច ហើយអាចដាក់បណ្តឹងសារទុក្ខផ្នែកពិន្ទុ ។
- ដើម្បីស្វែងយល់ព័ត៌មានពិស្តារបន្ថែមស្តីពីតេស្តរបស់រដ្ឋ, សូមមើលគេហទំព័រ ៖ http://www.WAtesting.com.

## វិញ្ញាបនប័ត្របញ្ជាក់ការបញ្ចប់ឧត្តមសិក្សា និងវិញ្ញាបនប័ត្របញ្ជាក់ ការបញ្ចប់ការសិក្សាឯកត្តជន

- **វិញ្ញាបនប័ត្រការបញ្ចប់ឧត្តមសិក្សា៖** ការតំរូវសំរាប់ ការទទួលសញ្ញាប័ត្រក្នុងការចាប់ផ្តើមថ្នាក់សិក្សាឆ្នាំ 2013 ។
- **វិញ្ញាបនប័ត្រការបញ្ចប់ឯកត្តជន៖** ការតំរូវសំរាប់តែសិស្សនៅក្នុងកម្មវិធីអប់រំពិសេសប៉ុណ្ណោះ ។ ល័ក្ខខ័ណ្ឌតម្រូវសំរាប់ការទទួលសញ្ញាប័ត្រ ក្នុងការចាប់ផ្តើមថ្នាក់សិក្សាឆ្នាំ 2013 ។ សិស្សគ្រប់រូបអាចទទួលបានសញ្ញាប័ត្រដោយប្រឡងជាប់ វិញ្ញាសារ HSPE-Basic, WAAS-Portfolio, WAAS-DAPE ឬវិញ្ញាសារវាស់ស្ទង់ចំណេះដឹងកំណត់ដោយមណ្ឌលសិក្សាធិការមូលដ្ឋានក្នុងការអាន សរសេរ គណិតសាស្ត្រ និងវិទ្យាសាស្ត្រ ។
- សិស្សគ្រប់រូបដែលបានសិក្សារហូតដល់ឆ្នាំ **2012** ដែលបានប្រឡងជាប់វិញ្ញាសាអាន សរសេរ គណិតសាស្ត្រ WASL/HSPE/WAAS ត្រូវទទួលបានវិញ្ញាបនប័ត្របញ្ជាក់ការបញ្ចប់ឧត្តមសិក្សា ឬវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាឯកត្តជន ។ **ឆ្នាំសិក្សា 2013 & 2014៖** ត្រូវតែប្រឡងជាប់ វិញ្ញាសាអាន សរសេរ និងគណិតសាស្ត្រ។ **ឆ្នាំសិក្សា 2015 ឡើងទៅ** ៖ ត្រូវតែប្រឡងជាប់វិញ្ញាសាអាន សរសេរ គណិតសាស្ត្រ និងវិទ្យាសាស្ត្រ។
- សិស្សគ្រប់រូបដែលបានសិក្សារហូតដល់ឆ្នាំ **2012** ដែលបានរៀនយកមុខវិជ្ជាគណិតសាស្ត្រឲ្យបាន ពីរក្រេឌិតបន្ទាប់ពីថ្នាក់ទី 10ប៉ុន្តែមិនបានប្រឡងប់វិញ្ញាសារគណិតសាស្ត្ររបស់រដ្ឋ ឬមុខវិជ្ជាតាមជំរើសជទៃដែលអនុម័តទទួលស្គាល់ដោយរដ្ឋ គឺក៏នៅតែមានលក្ខណសម្បត្តិទទួលសញ្ញាប័ត្រដែរ ប៉ុន្តែពួកគេមិនបានទទួលវិញ្ញាបនប័ត្រទេ។

## វិញ្ញាសាតាមជម្រើសទីទៃដែលអនុម័តទទួលស្គាល់ដោយរដ

- សិស្សដែលមានវិជ្ជាជំនាញការ ប៉ុន្តែមិនអាចបង្ហាញចេញនៅលើវិញ្ញាសាររបស់រដ្ឋ អាចប្រើវិញ្ញាសារ តាមជម្រើសជទៃៗទេឲ្យតដែលបានអនុម័តទទួលស្គាល់ដោយរដ្ឋបាន ។
- សិស្សគ្រប់រូបអាចទទួល CAA Option បន្ទាប់ពីធ្វើតេស្តរដ្ឋក្នុងគ្រប់មុខវិជ្ជានីមួយៗយ៉ាងតិចណាស់ឲ្យបានម្តង ។ សិស្សគ្រប់រូបត្រូវតែធ្វើតេស្តរដ្ឋយ៉ាងតិចណាស់ឲ្យបានពីរដង នៅមុនពេលទទួលការប្រមូលផ្តុំភស្តុតាង។
- ជម្រើសវិញ្ញាបនប័ត្រនៃ Certificate of Academic Achievement Options មានដូចតទៅ ៖
  - Collection of Evidence (ការប្រមូលផ្តុំភ័ស្តុតាង) – សិស្សអាចប្រមូលផ្តុំសំណៅកិច្ចការសិក្សារបស់ពួកគេ ដោយមានជំនួយពីគ្រូ(ៗ)របស់ពួកគេ។ ការប្រមូលផ្តុំសំណៅកិច្ចការសិក្សាសម្រាប់សិស្សក្នុងកម្មវិធីអប់រំវិជ្ជាជីវៈ និងបច្ចេកវេជ្ជា (Career and Technical Education programs)។ រដ្ឋឲ្យពិន្ទុលើកម្រងឯកសារប្រមូលផ្តុំនៃកិច្ចការសិក្សារបស់សិស្សពីរដងក្នុងមួយឆ្នាំ៖ សិស្សត្រូវចូលរួមប្រឡងរបស់រដ្ឋពីរដងក្នុងមួយផ្នែកសំខាន់ណាមួយមុនពេលព្យាយាមធ្វើការប្រមូលផ្តុំមួយ ។
  - ការលើកលែងតំលៃឈ្នួលគឺអាចមានសំរាប់សិស្សគ្រប់រូបដែលមានសិទ្ធិ ប្រឡង SAT, ACT និង AP ដែលបានអនុម័តយល់ព្រម។
  - SAT ឬ ACT – សិស្សអាចប្រើពិន្ទុក្នុងមុខវិជ្ជាគណិតសាស្ត្រ, អាន, ឬភាសាអង់គ្លេស និងសរសេររបស់ពួកគេ ទៅលើតេស្តត្រៀមចូលមហាវិទ្យា ល័យ។ ពិន្ទុខ្ពស់បំផុតគឺ ៖ **ការអាន** – SAT: 350 ACT: 13។ **ការសរសេរ** – SAT: 380 ACT: 15។ **គណិតសាស្ត្រ** – SAT: 470 ACT: 19។
  - Advanced Placement (AP) – សិស្សអាចប្រើពិន្ទុពីបី ឬច្រើនជាងនេះនៅលើវិញ្ញាសា AP ៖ **គណិតសាស្ត្រ** (គណនាអគ្រាល្ហ ឬស្ថិតិ); **ការសរសេរ** (ភាសាអង់គ្លេស និងការតែងសេចក្តី); និង**ការអាន** (អក្សរសិល្ប៍អង់គ្លេស និងការតែងសេចក្តី, ម៉ាក្រូសេដ្ឋកិច្ចសាស្ត្រ, មីក្រូសេដ្ឋកិច្ចសាស្ត្រ, ចិត្តសាស្ត្រ, ប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក, ប្រវត្តិសាស្ត្រពិភពលោក, រដ្ឋាភិបាល និងនយោបាយសហរដ្ឋអាមេរិក, ឬការប្រៀបធៀបរដ្ឋាភិបាល និងនយោបាយ)
  - ការប្រៀបធៀបពិន្ទុមធ្យមភាគ GPA – សម្រាប់តែសិស្សថ្នាក់ទី 12 ប៉ុណ្ណោះ។ ពិន្ទុរបស់សិស្សក្នុងមុខវិជ្ជាគណិតសាស្ត្រ និង/ឬភាសាអង់គ្លេសត្រូវ គេយក ទៅប្រៀបធៀបជាមួយនឹងពិន្ទុរបស់សិស្សនានាដែលរៀនមុខវិជ្ជាដូចគ្នា ហើយបានប្រឡងជាប់វិញ្ញាសា WASL/HSPE/EOC មធ្យមសិក្សាទុតិយ ភូមិ។ ដើម្បីប្រើជម្រើសនេះ, សិស្សត្រូវតែមានពិន្ទុមធ្យមភាគ (Grade Point Average – GPA) យ៉ាងតិចណាស់ 3.2 លើខ្នាតរង្វាស់ 4.0 ។
- ដើម្បីស្វែងយល់ព័ត៌មានពិស្តារបន្ថែមស្តីពីវិញ្ញាសាតាមជម្រើសទីទៃដែលអនុម័តទទួលស្គាល់ដោយរដ្ឋ,សូមមើលគេហទំព័រ ៖ http://www.k12.wa.us/assessment/CAAoptions.

## វិញ្ញាសាវាស់ស្ទង់ចំណេះដឹងសម្រាប់សិស្សក្នុងកម្មវិធីអប់រំពិសេស

- សិស្សគ្រប់រូបនៅក្នុងកម្មវិធីការសិក្សាពិសេសអាចធ្វើតេស្តរដ្ឋសម្រាប់មធ្យមសិក្សាទុតិយភូមិ ដោយមានរឺគ្មានការសម្របសម្រួលទៅតាមស្ថានការណ៍ ។
- វិញ្ញាសាតាមជម្រើសផ្សេងៗទៀតត្រូវបានបម្រុងជូនដូចតទៅ ៖
  - HSPE-Basic – សិស្សប្រឡងវិញ្ញាសា WASL/HSPE មធ្យមសិក្សាទុតិយភូមិ – ដោយមាន ឬដោយគ្មានការសម្របសម្រួល – ប៉ុន្តែក្រុម IEP បានកែសម្រួលជំនាញភាពនៃវិញ្ញាសាពី Proficient (Level 3) ទៅ Basic (Level 2) ។
  - Washington Alternate Assessment System Portfolio (កម្រងប្រព័ន្ធវាស់ស្ទង់ចំណេះដឹងបែបផ្សេងនៃរដ្ឋវ៉ាស៊ីនតោន, WAAS Portfolio) – សិស្សដែលមិនអាចប្រឡងដោយប្រើក្រដាសនិងខ្មៅដៃ អាចបង្ហាជំនាញ និងចំណេះដឹងនានារបស់ពួកគេតាមរយៈការប្រមូលផ្តុំសំណៅកិច្ចការ សិក្សារបស់ពួកគេ។
  - Developmentally Appropriate Proficiency Exam (វិញ្ញាសាជំនាញសមរម្យសម្រាប់សិស្សមានពិការភាព, WAAS-DAPE) – តែសិស្សក្នុងថ្នាក់ទី 11 និងទី 12 ប៉ុណ្ណោះ ប្រឡងវិញ្ញាសា WASL/HSPE – ដោយមាន ឬដោយគ្មានការសម្របសម្រួល – ក្នុងកម្រិតដែលសមស្របបំផុតទៅនឹងសមត្ថ ភាពរបស់ពួកគេ។ សិស្សប្រឡងជាប់ ដោយទទួលបានពិន្ទុក្នុងកម្រិត Level 3 លើវិញ្ញាសាទីមួយដែលពួកគេប្រឡង។
  - Locally Determined Assessments (វិញ្ញាសាវាស់ស្ទង់ចំណេះដឹងកំណត់ដោយមណ្ឌលសិក្សាធិការមូលដ្ឋាន) – សម្រាប់សិស្សថ្នាក់ទី 12 ដែលត្រូវការបទដ្ឋានសមិទ្ធិកម្មសិក្សាកែសម្រួល។
  - Awareness Level Waiver (វិញ្ញាសាអនុគ្រោះទៅតាមកម្រិតដែលខ្លួនដឹង) – មានបម្រុងសម្រាប់បណ្តាសិស្សដែលត្រូវបានគេរកឃើញថា អាចអនុវត្ត ការងារបានត្រឹមតែកម្រិត “ដែលខ្លួនដឹង” ប៉ុណ្ណោះ។
- ដើម្បីស្វែងយល់ព័ត៌មានពិស្តារបន្ថែមស្តីពីវិញ្ញាសាវាស់ស្ទង់ចំណេះដឹងសម្រាប់សិស្សក្នុងកម្មវិធីអប់រំពិសេស, សូមមើលគេហទំព័រ ៖ http://www.k12.wa.us/assessment/altassess.aspx.